**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ: ០២២/០៩ ក.ហ កកចយ

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០០៩

# កំណត់ហេតុ ស្តីពី កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីរពាន់ប្រាំបួន ខែ សីហា ថ្ងៃទីដប់ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី បន្ទប់ ២០៨ ជាន់ទីពីរ មានរៀបចំកិច្ចប្រជុំលើកទីបួនសំរាប់ឆ្នាំ២០០៩ របស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្រោមអធិបតីភាពរបស់ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ នៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកចម្រុះ ដើម្បីពិនិត្យពិភាក្សា លើការងារជាបន្ត ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនោះ ។ ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមប្រធានបានជម្រាបជូនអង្គប្រជុំអំពីរបាយការណ៍ភាពជឿនលឿនសូចនាករតាមដានរួម ដោយមាន អត្ថន័យជាអាទិ៍:

ឯកឧត្តមបានជម្រាបអង្គប្រជុំថា ក្រមព្រហ្មទណ្ឌបានដាក់ជូនទៅសភាជាតិកាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៩ សភាមានការឈប់សម្រាក ហេតុដូចនេះមិនមានការពិភាក្សា ចំពោះក្រមនេះនៅឡើយទេ ។ ច្បាប់ប្រឆាំង អំពើពុករលួយបានធ្វើរួច ត្រៀមបញ្ជូនទៅទីស្តីការ

គណៈរដ្ឋមន្ត្រី បន្ទាប់ពីក្រុមព្រហ្មទណ្ឌបានអនុម័តរួច ។ ចំណែកឯ ច្បាប់ផ្សេងៗទៀត ដែលទាក់ទងនឹងតុលាការកំពុងស្ថិតនៅជាមួយនឹងក្រុមការងារដោយឡែកៗ រៀងៗខ្លួន ។

## ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ជាតិបច្ចុប្បន្នបច្ចុប្បន្ន (២០០៩-២០១៣)

ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បាន ជម្រាបជូនអង្គប្រជុំថា សេចក្តីព្រាងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ ផែនការយុទ្ធសាស្ត្រជាតិ ដើម្បីអភិវឌ្ឍន៍បច្ចុប្បន្នកម្ម (២០០៩-២០១៣) មានបកប្រែជាភាសាអង់គ្លេស ហើយបានផ្ញើទៅក្រសួងផែនការកាលពី ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ ។ អត្ថបទព្រាងនេះមានពីរផ្នែកៈ

1- វឌ្ឍនភាព នៃការអនុវត្ត នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានដូចជា ការចូលជាធរមាននូវក្រម រដ្ឋប្បវេណីជាដើម ។ ក្រមព្រហ្មទណ្ឌមិនទាន់មាន ការអនុម័តពីសភាជាតិនៅឡើយទេ ចំណែកផែនការ យុទ្ធសាស្ត្ររបស់តុលាការ គំរូបានរៀបចំរួចហើយ និងបានលើកសំណើថវិកាទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០១០ ។ យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបច្ចុប្បន្ននេះ កំពុងដំណើរ ការសាកល្បង ចំណែកការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា ក៏កំពុងអនុវត្តដែរ ។

2- ទិសដៅបន្ត គឺការអនុម័តក្រម និងច្បាប់ ។ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវច្បាប់ថ្មីៗទាំងឡាយ ក៏ជា តម្រូវការផងដែរ ។ មានវគ្គបណ្តុះបណ្តាលជាបន្តដល់ ចៅក្រម និងព្រះរាជអាជ្ញា ដើម្បីបន្ថែមនូវសមត្ថភាព ឱ្យកាន់តែប្រសើរឡើង ។ ការបណ្តុះបណ្តាលបឋមក៏ត្រូវផ្តោតការយកចិត្តទុកដាក់ដែរ ។ យន្តការផ្តល់ សេវាយុត្តិធម៌ និងច្បាប់ឱ្យមានប្រសិទ្ធិភាពតម្រូវឱ្យមានការពិនិត្យពិចារណា ហើយ ជំនួយផ្នែកច្បាប់ ត្រូវ តែបន្តការគាំទ្របែមទៀត ។ ចំណែកឯយន្តការដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការវិញ យើងត្រូវតែ អភិវឌ្ឍបន្ថែម ។

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ក្រសួងផែនការបានអញ្ជើញក្រុមការងារ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិ ធម៌ ចូលរួមពិភាក្សាអំពីករណីខាងលើ និងអំពីគំរូរៀបចំ ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បច្ចុប្បន្នកម្ម (២០០៩-២០១៣) ។ មានការតម្រូវឱ្យពិនិត្យ មើលទៅលើសកម្មភាពដែលបានធ្វើឡើងវិញ ព្រោះថា ពេលវេលាសម្រាប់បញ្ចូល ទៅក្នុង ផែនការជាតិនោះក៏នៅយូរដែរ ។

ឯកឧត្តមប្រធានបានស្នើឱ្យអង្គប្រជុំផ្តល់មតិយោបល់ចំពោះទម្រង់បែបបទថ្មីនេះ ។

លោកស្រី Arthi Patel, 1st Secretary DC, AusAid បានធ្វើការកត់សំគាល់អំពីសារៈ សំខាន់ នៃកំណែទម្រង់តុលាការ ហើយបានរំលឹកពីការប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដែលយកផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិជាចំណុចយោង ដូច្នេះចាំបាច់ត្រូវមានយោបល់លើកំណែទម្រង់តុលាការថ្នាក់ជាតិទាំងមូល មិនមែនតែ លើតុលាការគំរូប៉ុណ្ណោះទេ ។ បញ្ហាមួយទៀតទាក់ទងទៅនឹងច្បាប់នគរបាល និងមន្ត្រីពន្ធនាគារ ដែលកំពុងតែរៀបចំ ហើយការនេះក៏ត្រូវការជំនួយគាំទ្រ សម្រាប់ការអភិវឌ្ឍន៍ និងការអនុវត្តជាបន្តទៅមុខទៀតផងដែរ ។

ឯកឧត្តមប្រធានអង្គប្រជុំបានកត់សំគាល់ថា នេះគឺជាដំណើរការ នៃការចូលរួម ហើយការធ្វើផែនការយុទ្ធសាស្ត្រ របស់ក្រសួងយុត្តិធម៌ ក៏ជាការទាក់ទាញរកមូលនិធិបានច្រើនដែរ ប្រសិនបើរៀបចំបានល្អ ។ ដៃគូអភិវឌ្ឍន៍ត្រូវបានស្នើសុំ ឱ្យធ្វើអនុសាសន៍ មុនកាលបរិច្ឆេទចុងក្រោយ ។

ឯកឧត្តម ច័ន្ទ មនោ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងយុត្តិធម៌ បានជម្រាបជូន អង្គប្រជុំថា នៅក្នុងខែមិថុនា ឆ្នាំ២០០៩ នេះ ក្រុមការងារធ្វើផែនការបានធ្វើការជួបគ្នានៅក្នុងក្រសួងយុត្តិធម៌ ដើម្បីឱ្យ ដំណើរការឈានទៅមុខ ។ មានប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋានបានចូលរួមក្នុងសិក្ខាសាលាអំពីការធ្វើ ផែនការនៅខេត្តកំពង់សោម ហើយសិក្ខាសាលាមួយថ្ងៃទៀតនឹងធ្វើនៅភ្នំពេញ ។ ការប្រជុំបីលើកបានធ្វើនៅក្នុងខែ កក្កដា ហើយនឹងត្រូវធ្វើមួយដង ឬពីរដងទៀត មុននឹងដាក់ឆ្លងឯកឧត្តមរដ្ឋមន្ត្រី ។

បន្ទាប់ពីសិក្ខាសាលានៅកំពង់សោមមក ទាំងចក្ខុវិស័យ បេសកកម្ម និងទិសដៅទាំងបួនត្រូវបានកំណត់ សម្រាប់ ក្រសួងយុត្តិធម៌ទាំងមូល ។ គោលដៅទាំងបួនគ្របដណ្តប់លើៈ

- ច្បាប់ និងព័ត៌មានអំពីច្បាប់
- ការពង្រឹងធនធានផ្នែកច្បាប់ និងតុលាការ
- ការពង្រឹងការអនុវត្តច្បាប់
- ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវអធិការកិច្ចលើរឿងក្តី ។

ក្រសួងយុត្តិធម៌បានស្នើសុំឱ្យ CCJAP បន្តជួយសំណើខាងលើ និងស្នើសុំធ្វើសិក្ខាសាលាមួយផ្តោតលើការរៀបចំ ផែនការសកម្មភាព ។ ជាមួយនឹងផែនការសកម្មភាពល្អ ដែលអនុលោមតាមផែនការយុទ្ធសាស្ត្រនោះមានការរំពឹង ទុកថា ក្រសួងយុត្តិធម៌នឹងមានភាពរីកចំរើនទៅមុខ ។ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានស្នើឱ្យមាន ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ក៏ដូចជាផែនការសម្រាប់ការគាំទ្រដល់ការអនុវត្តតុលាការគំរូផងដែរ ។ ផែនការយុទ្ធសាស្ត្រធ្វើឱ្យមានការងាយស្រួលក្នុងការប្រមូលផ្តុំការឧបត្ថម្ភគាំទ្រ ហើយនឹងធ្វើឱ្យប្រាកដចំពោះការងារ របស់ក្រសួងយុត្តិធម៌ក្នុងការគាំទ្រដល់ការអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ក្រសួងយុត្តិធម៌បានកត់ សំគាល់ឃើញថា នៅខណៈពេលរៀនផងធ្វើការផង មិនអាចទទួលបាននូវលទ្ធផលល្អឥតខ្ចោះនោះទេ ។ ក្រសួងយុត្តិធម៌ មានការលំបាកច្រើន ដោយសារក្រសួងនៅខ្វះខាតផ្នែកថវិកា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រតុលាការគំរូ ហើយបានលើកឡើងថា មានការលំបាកក្នុងការគាំទ្រតុលាការគំរូ ពិព្រោះចំពេលដែលមានវិបត្តសេដ្ឋកិច្ចពិភពលោក ។ ដូច្នេះអាចបន្ថយការស្នើ សុំមកត្រឹមតែតុលាការគំរូណាមួយវិញ ហើយធ្វើឱ្យត្រូវស្តង់ដារអន្តរជាតិ ។

ឯកឧត្តមប្រធានអង្គប្រជុំបានលើកសរសើរដល់ក្រសួងយុត្តិធម៌ ដែលបានខិតខំប្រឹងប្រែងលើផែនការយុទ្ធសាស្ត្រ មិនតែប៉ុណ្ណោះក្រសួងយុត្តិធម៌ ក៏ជាភ្នាក់ងារដ៏សំខាន់ក្នុងការកែទម្រង់ដែរ ។ ឯកឧត្តមបានមានប្រសាសន៍បន្តទៀត ថា ជាការល្អណាស់ដែលបានឮថាថវិកាសម្រាប់តុលាការគំរូបានចូលទៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយពេលនេះយើងត្រូវការការពិចារណាដើម្បីរិះរកមធ្យោបាយឡើងវិញក្នុងការរៀបចំសំណើសុំថវិកានេះ ។ ការស្នើសុំថវិកាណាមិន មែនសម្រាប់ដំណើរការទាំងស្រុងរបស់តុលាការគំរូក្នុងឆ្នាំ២០១០ សម្រាប់អាទិភាពខ្លះដែលត្រូវពិភាក្សាគ្នានាពេលនេះ ។

លោក Michael Engquist, Senior Programme Officer, Danida បានមានប្រសាសន៍ថា ក្រសួងយុត្តិធម៌ អាចពិនិត្យរៀបចំផែនការថវិកាជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុម្តងទៀត ពិព្រោះថា នៅមានរយៈពេលពីរខែទៀត ដើម្បីធ្វើការងារនេះ ។ AusAid និងដានិដា បានជួបលោកបណ្ឌិត សុខ សារាវុឌ្ឍ ប្រធាននាយកដ្ឋានក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងថវិកា ដែលបានគូសបញ្ជាក់ថា នីតិវិធីត្រូវតែគោរពឱ្យបានត្រឹមត្រូវ ។

បណ្ឌិត រស់ ឆាយ ខាង AusAid បានបញ្ជាក់ថា លោកបានជួបជាមួយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ហើយថាមាន គោលការណ៍បួនទាក់ទងទៅនឹងសំណើសុំថវិកានេះ គឺ ៖

១- ផែនការយុទ្ធសាស្ត្រ
និងផែនការថវិកាត្រូវបង្ហាញនូវទំនាក់ទំនងទៅនឹងផែនការអភិវឌ្ឍន៍ យុទ្ធសាស្ត្រ ជាតិ (NSPD) តាម រយៈកម្មវិធីថវិកាកម្ម

២- ក្រសួងត្រូវបង្ហាញនូវភាពជាម្ចាស់ និងជាអ្នកអនុវត្តនូវគម្រោង

៣- ក្រសួងជាអ្នកស្នើសុំថវិកា

៤- ធ្វើយ៉ាងណាឱ្យមានការតាមដាន និងការវាយតម្លៃច្បាស់លាស់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចង់ឱ្យមានការច្បាស់លាស់ ថាតើក្រសួងយុត្តិធម៌ ឬក៏ក្រុមប្រឹក្សាកំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាអ្នកស្នើសុំថវិកា ។ ថ្វីត្បិតតែកង្វះខាតថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងខិតខំប្រឹងប្រែងដោះស្រាយបញ្ហានេះ ។

ឯកឧត្តម ច័ន្ទ មនោ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ បានបញ្ជាក់ថា បន្ថែមលើអ្វីដែល បណ្ឌិត រស់ ឆាយ បានលើកឡើង

ទាក់ទងដល់គោលការណ៍ទាំងបួននេះ ឯកឧត្តមបានឯកភាពថា ពិតជាត្រឹមត្រូវ ។ ហើយឯកឧត្តមបានពន្យល់ទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីការងារដែលក្រសួងយុត្តិធម៌បានរៀបចំក្នុងការធ្វើការស្នើសុំថវិកា ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើឱ្យមានព័ត៌មានលំអិតបន្ថែមទៀត ។ ផែនការយុទ្ធសាស្ត្ររបស់ ក្រសួងត្រូវរៀបចំឱ្យបានច្បាស់លាស់ ដើម្បីជួយគាំទ្រដល់សំណើនេះ ហើយការទទួលខុសត្រូវ ចំពោះការគ្រប់គ្រងថវិកា និងស្ទូចនាការតាមដានក៏ត្រូវតែបញ្ជាក់ ចំណែកឯក្រុមការងារតុលាការគំរូរបស់ក្រសួង គឺជាអ្នកដើរតួសំខាន់ក្នុងការ ការពារសំណើថវិការរបស់តុលាការគំរូនេះ ។

លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានមានប្រសាសន៍ថា បន្ទាប់ពីបង្កើត បានពីរខែកន្លងទៅនេះ ក្រុមការងារបានខិតខំធ្វើការយ៉ាងខ្លាំង ដោយមានការចូលរួមពី AusAid, Danida, Usaid, Ccjap, EWMI &Focal Point ពីខាងតុលាការគំរូ ។ ដោយសារការងារ នៅសេសសល់ ដូច្នេះត្រូវបន្តធ្វើសិក្ខាសាលា មួយឱ្យបានមុនបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ដើម្បី ៉ រៀបចំផែនការសកម្មភាព ៉ ដោយមានការចូលរួមពី Focal Point តុលាការគំរូទាំងបួន ។

ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថ្លែងអំណរគុណចំពោះការខំប្រឹងប្រែងរួមគ្នាដល់ឯកឧត្តម លោក ជំទាវទាំងអស់ និងបញ្ជាក់ថា នេះជារបៀបធ្វើការដែលជាការចាំបាច់សម្រាប់ធ្វើឱ្យការងារដើរទៅមុខ ហើយអ្វីដែល លោកជំទាវរដ្ឋលេខាធិការ ចាន់ សុទ្ធាវី បានលើកឡើងគឺពិតជាត្រឹមត្រូវ និងច្បាស់លាស់ណាស់ ហេតុនេះឯកឧត្តម បានផ្តាំផ្ញើតាមក្រសួងយុត្តិធម៌ សូមឱ្យជម្រាបទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឱ្យជួយផ្តល់ថវិកាខ្លះមិនមែនទាំង ស្រុងនោះទេ គឺតាមលទ្ធភាពដែលអាចជួយបាន ។

ចំពោះសកម្មភាពរបស់តុលាការគំរូ ខាង CLJR បានបញ្ចូលទៅក្នុងរបាយការណ៍ដាក់ជូនសម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន ដើម្បីរាយការណ៍ថ្វាយព្រះមហាក្សត្រកន្លងទៅរួចហើយ ។

ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បាន ជម្រាបជូនថា នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្មសំណើថ្មី មានដាក់បញ្ចូលគម្រោងតុលាការគំរូ រួចហើយ ។

លោកស្រី Arthi Patel 1st, Secretary AusAid បានកោតសរសើរចំពោះការប្រឹងប្រែងរបស់ក្រសួង យុត្តិធម៌ ហើយលោកស្រីមានការបារម្ភផង ចំពោះការអនុវត្តតុលាការគំរូ ។ ទាក់ទងទៅ នឹងការផ្តល់ថវិកាពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០១០ លោកស្រីបានជម្រាបថា ការផ្តល់ថវិកានេះនឹងផ្តោតតែទៅលើតុលាការគំរូ តែប៉ុណ្ណោះ ដូច្នេះលោកស្រីគិតថា គួរតែលើកឡើងនូវការគិតគូរក្នុងការពង្រីកទៅតុលាការទាំងមូលផងដែរ ។

ចំនួន ថវិកាស្នើសម្រាប់ឆ្នាំ២០១០ប្រហែលជាតិចជាងតម្រូវការ ដូច្នេះតុលាការគួរតែជាចំណែក នៃដំណើរការបែងចែកថវិកា រដ្ឋដែរ ។

លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានកត់សំគាល់ថា លុះត្រាតែយើងបានដឹងពី អាទិភាពរបស់តុលាការគំរូទាំងបួន និងបញ្ហាមួយចំនួន ។ សម្រាប់កិច្ចប្រជុំខាងមុខមានការសម្រេចថា នឹងពិភាក្សាគ្នា អំពីផែនការសកម្មភាព និងសកម្មភាពចំពោះមុខ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ផែនការនោះមិនអាចផ្តោតទៅលើគម្រោងទាំងមូលទេ តែត្រូវធ្វើការផ្តល់អាទិភាព ។ តុលាការគំរូ គឺជា ផ្នែកមួយរបស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ នៅក្នុងការប្រជុំនោះ អ្នកផ្តល់ជំនួយផ្សេងៗ នឹងត្រូវអញ្ជើញឱ្យ ចូលរួម ។

ឯកឧត្តមប្រធានបានបញ្ជាក់ជូនអង្គប្រជុំថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តម្រូវឱ្យមានការកំណត់ សូចនាករតាមដានឱ្យបានច្បាស់លាស់ ដូចេះឯកឧត្តមសូមអញ្ជើញ កញ្ញា Lise G.Hendriksen, Project Coordinatior, DIHR លើកឡើងបង្ហាញពីគម្រោង សូចនាករតាមដាន នេះដែលទាក់ទងដល់ការអនុវត្ត គម្រោងតុលាការគំរូ ។

កញ្ញា Lise អ្នកសម្របសម្រួលថ្មីមកពីវិទ្យាស្ថានសិទ្ធិមនុស្សនៅដាណឺម៉ាកបានបញ្ជាក់ ជូនអង្គប្រជុំថា ការរៀបចំផែនការតុលាការគំរូ គឺអនុវត្តតាមគោលការណ៍ នៃតុលាការគំរូ ហើយប្រព័ន្ធសូចនាករតាមដាន គឺជាមធ្យោបាយតាមដានការអនុវត្តតុលាការគំរូ ។ លក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវបានរៀបចំ ដើម្បីប្រមូល ទិន្នន័យសម្រាប់ការតាមដាន ផលប៉ះពាល់ នៃតុលាការគំរូ ។ កញ្ញាបានជម្រាបជូនអង្គប្រជុំថា អាទិត្យក្រោយ នឹងមាន អ្នកជំនាញខាងសូចនាករតាមដាន ចំនួន២រូបទៀត អញ្ជើញមកធ្វើការរឿងនេះ ។

ឯកឧត្តមប្រធានអង្គប្រជុំបានបញ្ជាក់ឡើងវិញថា នៅអាទិត្យក្រោយនឹងមាន អ្នកជំនាញខាងសូចនាករ តាមដាន និងការវាយតម្លៃមកពីប្រទេសដាណឺម៉ាក ហើយឯកឧត្តម នឹងអញ្ជើញពួកគាត់ឱ្យទៅជួបក្រុមការងារ របស់ក្រសួងយុត្តិធម៌ក្នុងការរៀបចំផែនការថវិកា និងពិភាក្សាពីបញ្ហាការអនុវត្តតុលាការគំរូ ។

លោកស្រី Arthi Patel 1st, Secretary AusAid បានមានប្រសាសន៍ថា សូចនាករតាមដានរួមបច្ចុប្បន្ននេះ មានបញ្ចូលការអនុវត្តការចុះបញ្ជីនៅតុលាការទាំងបួន ដូច្នេះមានការចាំបាច់ត្រូវពិចារណាអំពីប្រព័ន្ធ នៃការចុះបញ្ជី នេះ ។

ឯកឧត្តមប្រធានបានឯកភាពចំពោះប្រការនេះ ហើយបានបញ្ជាក់ថា សព្វថ្ងៃកំពុងអនុវត្ត នៅតុលាការកណ្តាល ។ ចំពោះបញ្ហាផ្សេងៗ ឯកឧត្តមប្រធានសូមឱ្យដៃគូអភិវឌ្ឍន៍បញ្ជាក់ថា តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យបានលទ្ធផលជាក់ស្តែង នៅក្នុងកំណែទម្រង់ច្បាប់ និងតុលាការ ។

លោក Michael Enquist, Senior Programme Officer, DANIDA មានប្រសាសន៍ថា ច្បាប់ជា មូលដ្ឋានគ្រឹះដែលនៅសេសសល់មិនទាន់អនុម័តត្រូវពិនិត្យឡើងវិញ ។ DANIDA មានការពេញចិត្តចំពោះការសម្រេច បាននូវផែនការយុទ្ធសាស្រ្តតុលាការគំរូទាំងបួន និងការដែល ក្រសួងយុត្តិធម៌ រ៉ាប់រងនូវដំណើរការនេះ ។ ជាមួយគ្នានោះ ដែរ លោកបានលើកថា ការទាក់ទងដល់ករណីបណ្តឹងបរិហារកេរ្តិ៍នៅពេលបច្ចុប្បន្ននេះអាចមានផលប៉ះពាល់ដល់ជំនឿ ទុកចិត្តរបស់ប្រជាពលរដ្ឋ និងអ្នកផ្តល់ជំនួយចំពោះតុលាការ ។ លោកក៏បានលើកផងដែរ ពីករណីពិសេសមួយចំនួន រួមទាំងករណីដីធ្លីនៅខេត្តរតនៈគីរី ហើយការដាក់បន្ទុកលើ តំណាងអង្គការ ADHOC នៅក្នុងខេត្ត និងផលប៉ះពាល់ ដល់ជំនួយរបស់ DANIDA ចំពោះកម្មវិធីរបស់អង្គការ ADHOC នៅក្នុងខេត្ត ក៏ដូចជាគម្រោងការគ្រប់គ្រងធនធាន ធម្មជាតិ និងកម្មវិធីផ្សេងៗទៀត ។

ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថា យើងកំពុងស្ថិតនៅក្នុងដំណាក់កាល នៃការអភិវឌ្ឍន៍នៅឡើយ ហើយនៅត្រូវការជំនួយឧបត្ថម្ភ ។ បញ្ហាលើកឡើងទាំង ប៉ុន្មានបញ្ជាក់ថា យើងត្រូវបន្តលើកកំពស់ប្រព័ន្ធការងារយើង ថែមទៀត ។ ត្រូវមាន ការប្តូរផ្លាស់នៅក្នុងប្រព័ន្ធ ហើយយើងក៏បានព្យាយាមពង្រឹងក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុម ប្រឹក្សា នៃអង្គចៅក្រម និងបានចាត់វិធាន ដាក់វិន័យទៅលើចៅក្រម និងអយ្យការជាច្រើនមកហើយ ។ យើងបានចាត់ វិធានការចំពោះចៅក្រម និងព្រះរាជអាជ្ញាចំនួន១០៨នាក់ ប៉ុន្តែនៅតែមាន អ្នកធ្វើខុសដដែល ។ ឯកឧត្តមបានស្នើសុំឱ្យ អង្គប្រជុំជួយផ្តល់ជាមតិយោបល់តាមរយៈ អាស័យដ្ឋានអ៊ីម៉ែល ។ ជាមួយគ្នានោះដែរ ឯកឧត្តមប្រធានបានសម្តែងពីការ រីករាយចំពោះ លទ្ធផលសម្រេចបានជាង៦០ភាគរយពីការងារកែទម្រង់ ទោះបីជាមិនទាន់បាន១០០ ភាគរយ ក៏ដោយ ។

លោកស្រី Arthi Patel តំណាងAusaid បានមានមតិថា សិក្ខាសាលាថ្នាក់ជាតិខាង មុខនេះ ជាឱកាសមួយ ដែលយើងត្រៀមបង្ហាញទាំងការលំបាក និងការសម្រេចនូវសមិទ្ធិផល ហើយក៏ជាឱកាសមួយដើម្បីស្នើសុំនូវការគាំទ្រ បន្ថែមផ្នែកនយោបាយ ។

លោកស្រី Momoko Hotta, Assistant Resident Representative, JICA បានជម្រាបជូន អង្គប្រជុំទាំងមូលពីការធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសជប៉ុនវិញនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ ហើយលោកស្រី បានសម្តែងពីអារម្មណ៍របស់លោកស្រីក្នុង ការធ្វើការងារ ជាមួយនឹងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កន្លងមកថា លោកស្រី ពិតជាមានការរីករាយយ៉ាងខ្លាំងចំពោះការសហប្រតិបត្តិការជាមួយនឹងក្រុមប្រឹក្សាកំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ជាចុងក្រោយឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណចំពោះលោកស្រី Momoko Hotta ដែល បានជួយជ្រោមជ្រែងបានសម្រេចនូវលទ្ធផលយ៉ាងល្អកន្លងមក ។ ហើយ ឯកឧត្តមបានសម្រេចថា កិច្ចប្រជុំក្រុមការងារ បច្ចេកទេសចំរុះលើកក្រោយនឹងប្រព្រឹត្តទៅ នៅថ្ងៃចន្ទ័ ទី០៥ ខែតុលា ឆ្នាំ២០០៩ ខាងមុខនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោង៤ និង៣០ នាទីល្ងាចនា ថ្ងៃខែឆ្នាំ ដដែល ។

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ** **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង រ៉ាន់ដា**

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩

០១-ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ ក.ក.ច.ន.យ

០២-ឯកឧត្តម សួង លាងហៃ អគ្គលេខាធិការរង ក.ក.ច.ន.យ

០៣-ឯកឧត្តម ផៃ សុខខេង ប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
០៤- ឯកឧត្តម បួន សុមុនី អគ្គលេខាធិការរង ក.ក.ច.ន.យ
០៥- លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌
០៦- ឯកឧត្តម ប្រុក សារឿន ប្រធានក្រុមនីតិកម្ម ក្រសួងមហាផ្ទៃ
០៧-ឯកឧត្តម ច័ន្ទ មនោ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌
០៨-ឯកឧត្តម ផៃ លី អនុប្រធានផ្នែកកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
០៩- លោកស្រី សាខឿន សាវ៉ាត់ឌី ក្រសួងកិច្ចការនារី
១០-សុង សុខភារម្យ
អនុប្រធាននាយកដ្ឋានជំនួយការកិច្ចការតុលាការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម9្យជំប
១១-លោក ជឹង ផេងស្រួយ ប្រធានផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
១២-ះនេង Sokheang, ACU
១៣-ំាខ Howlett, EWMI
១៤-េាវតហិ Patel, First secretary (AusAid)
១៥-ឡិសេ Dahl, UNDP
១៦-គហោានង Seng, ACU
១៧-ំរ។ Peter May, Court Advisor,CCJAP
១៨-ឡសេលយេ Miller ( UNICEF Chief Child Protection )
១៩-ភៀក Phira, Staff, Jica
២០- James Turpin, Rule of Law Programme
២១- Ben Schultz, Adviser (CCJAP III)
២២-្យនេង Rethy, Rule of Law Specialist ( USAID)
២៣-្វៀនង Ton, OHCHR
២៤-្រេដេ Aeschliman, USAID
២៥-លោក ឃ្លោក ដារ៉ា ប្រធានផ្នែកលើកកំពស់សិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
២៦-លោក ឆុង ហួត ប្រធានផ្នែកកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
២៧-លោក តុង ពាវ អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌
២៨-លោកស្រី ស្រី ប៊ុណ្ណាវ័ត្ន អនុប្រធានផ្នែកបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
២៩-លោកស្រី យិន កក្កដា ប្រធានការិយាល័យ នៃកកចយ
៣០-លោកស្រី សេង វ៉ាន់ដា ប្រធានការិយាល័យ នៃកកចយ
៣១-លោក ស៊ុន សិរីវុធ ជំនួយការរដ្ឋបាលបុគ្គលិក និងហារិញ្ញវត្ថុ
៣២-កញ្ញា ផាន ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ
៣៣-លោក សួន វិរៈ មន្ត្រី ក.ក.ច.ន.យ
៣៤-លោក ហួរ ភត្រា មន្ត្រី ក.ក.ច.ន.យ